## ៨-១-៥ បុណ្យភ្ជុំបិណ្ឌ

បុណ្យដែលគេបាន ដាក់បិណ្ឌ ឬកាន់បិណ្ឌ អស់ ១៤ ថ្ងៃ ចាប់ពីថ្ងៃ ១ រោច រហូតដល់ ១៤ រោច ខែភទ្របទ ហើយគេមកជួបជុំគ្នា ប្រគេនចង្ហាន់ព្រះសង្ឃ បញ្ចប់ក្នុងថ្ងៃ ១៥ រោច ខែភទ្របទ បុណ្យនោះគេហៅថា "បុណ្យភ្ជុំបិណ្ឌ" ។

បិណ្ឌ ប្រែថា បាយ ដុំបាយ ចង្ហាន់ ដាក់បិណ្ឌគឺដាក់បាយ ឬ ដាក់វេនគ្នាប្រគេនបាយ ដល់ ព្រះសង្ឃ ។

កាន់បិណ្ឌ គឺកាន់យក ប្រកាន់យក ទទួលយកថ្ងៃណាមួយដើម្បីប្រគេនបាយ ដល់ព្រះសង្ឃ ។

ចំណែកថ្ងៃចុងក្រោយបំផុត គឺថ្ងៃ១៥រោច មិនឲ្យនរណាប្រកាន់យកទេ គឺត្រូវទុក ជាថ្ងៃមកធ្វើរួមគ្នា ជួបជុំគ្នា ទើបគេឲ្យឈ្មោះថា ថ្ងៃ "ភ្ជុំបិណ្ឌ" (បុណ្យភ្ជុំបិណ្ឌ) ។

បុណ្យកាន់បិណ្ឌ (ពី ១ រោច ទៅ ១៤ រោច ) និង ភ្ជុំបិណ្ឌ(ថ្ងៃ១៥រោច) មានពិធី ចំរើនបរិត្តរាប់បាត្រ ស្តាប់ធម៌ទេសនា ដូចបុណ្យឯទៀតដែរ។ ប៉ុន្តែមានលក្ខណៈ ពិសេសរបស់ខ្លួនដូចតទៅនេះ៖

១- ធ្វើបានតែក្នុងរនោចខែភទ្របទ ជាកំណត់,

២-ធ្វើដើម្បីឧទ្ទិសចំពោះអ្នកស្លាប់ជារឿងសំខាន់,

៣-ត្រូវតែមានបាយដំណើប នំអន្សម នំគម(ស្រុកខ្លះមានហែបាយបិណ្ឌបោះ បាយបិណ្ឌផង),

៤- ត្រូវតែសូត្របទ **បរាភវសូត្រ** ផង,

៥-ចំពោះថ្ងៃ១៤ រោច នៅតាមផ្ទះ គេវេចនំអន្សម នំគម ដើម្បីធ្វើបុណ្យ ធ្វើទានផង ។

នៅទីវត្តមាន ធ្វើពុទ្ធាភិសេកនៅពេលយប់ (គេយកបាយបិណ្ឌមួយថ្ងៃមួយពំនូត យកមកខ្ចុកធ្វើជាព្រះពុទ្ធរូបហៅថា ព្រះបាយ ឬ យកព្រះពុទ្ធរូបថ្មីឯទៀតជំនួសក៏បាន)

៦-ចំពោះថ្ងៃ១៥កេច ពេលព្រឹកគេធ្វើបុណ្យនៅវត្ត ពេលល្ងាចនៅតាមផ្ទះគេរៀបចំម្ហូប ចំណី សែនដូនតា ហើយព្រឹកស្អែកឡើង គេជូនដំណើរដូនតា ត្រឡប់ទៅវិញ។

<u>សង្កេត</u> :

១-ក្នុងបាលីនិងអដ្ឋកថា មិនមាននិយាយរឿងភ្ជុំបិណ្ឌទេ ប៉ុន្តែមាននិយាយច្រើន រឿងបុណ្យឧទ្ទិសកុសល ចំពោះអ្នកស្លាប់ ។

២-មាននិទាន មិនមែនតែក្នុងប្រទេសកម្ពុជាទេ ក្នុងប្រទេសឯទៀត ក៏មានដែរ តំណាលថា: នាយនិរយបាល បានបើកទ្វារឲ្យសត្វនរកប្រេត ចេញទៅទទួលផលបុណ្យ ពីពួកញាតិមិត្រ ក្នុងរដូវវស្សាឦត (រនោចខែកទ្រុបទ) ព្រោះសត្វ ពួកនោះមានសេចក្តីភ័យខ្លាចច្រើន អែបៗ តាមទីងងឹតៗ តែប៉ុណ្ណោះ ។

៣-ក្នុងប្រទេសឯទៀតគេមានធ្វើបុណ្យឧទ្ទិសចំពោះអ្នកស្លាប់ក្នុងរដូវវស្សាឦតដែរ ប៉ុន្តែគេធ្វើបុណ្យតែ ១ ថ្ងៃទេ ។

៤-សន្និដ្ឋានដោយមានហេតុដូចពោលហើយផង ដោយក្នុងរដូវនោះមានភ្លៀង មានទឹកច្រើនផង ព្រះសង្ឃពិបាកបិណ្ឌបាតផង បានជាអ្នកប្រាជ្ញនិងអ្នកមានសទ្ធានាំគ្នាធ្វើបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌឡើង ។ តាមលទ្ធភាព គេអាចលៃធ្វើបុណ្យកាន់បិណ្ឌរាល់ថ្ងៃ ឬបន្ថយចំនួនថ្ងៃកាន់បិណ្ឌ និង ចំនួនព្រះសង្ឃដែលត្រូវវេនទៅទទួលភត្តឲ្យសមល្មម តាមកម្លាំងរបស់គេបាន។ ទិសដៅរបស់បុណ្យ កាន់បិណ្ឌ ភ្ជុំបិណ្ឌ គឺដើម្បីមនុស្សស្លាប់ ច្រើនជាង មនុស្សរស់ ៕

វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ “ ← “ ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។